Phnom Penh Post

# សេដ្ឋកិច្ច

www.postkhmer.com

## GEផ្គត់ផ្គង់ឧបករណ៍សាងសង់រោងចក្រថាមពលនៅកម្ពុជា

ហ៊ា គីមសាយ

**ភ្នំពេញ:** ក្រុមហ៊ុនផលិតថាមពលដ៏ធំមួយរបស់អាមេរិក GE Power ដែលបោះបញ្ជីក្នុងផ្សារហ៊ុនក្រុងញូវយ៉ក កាលពីម្សិលមិញបានចុះកិច្ចសន្យាផ្គត់ផ្គង់ឧបករណ៍ដល់ក្រុមហ៊ុនជប៉ុន Toshiba Plant System & Services Corporation (TPSC) ដើម្បីសាងសង់រោងចក្រអគ្គិសនីដើរដោយធ្យូងថ្មមានអានុភាព ១៣៥ មេហ្គាវ៉ាត់ក្នុងខេត្តព្រះសីហនុ។

នេះជារោងចក្រអគ្គិសនីដើរដោយធ្យូងថ្មទី៣នៅកម្ពុជាគិតមកទល់ពេលនេះ ដែលមានទីតាំងនៅស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ និងជាកិច្ចព្រមព្រៀងដែលមានក្រុមហ៊ុន៣ផ្សេងគ្នាចូលរួម។



ពិធីចុះកិច្ចព្រមព្រៀងរវាងក្រុមហ៊ុន GE និងក្រុមហ៊ុន Toshiba នៅស្ថានទូតអាមេរិកប្រចាំកម្ពុជាកាលពីថ្ងៃម្សិលមិញ ។ រូបថត ហេង ជីវ័ន

រោងចក្រនេះគឺជាការវិនិយោគដោយក្រុមហ៊ុន Cambodia Energy II Co, Ltd (CEL II) ដោយក្រុមហ៊ុនបានជួលក្រុមហ៊ុនជប៉ុន TPSC ជាអ្នកទទួលសិទ្ធិផ្នែកវិស្វកម្ម លទ្ធកម្ម និងសាងសង់។

នៅក្នុងកិច្ចព្រមព្រៀងកាលពីម្សិលមិញ ក្រុមហ៊ុន TPSC បានទិញកញ្ចប់សេវាថាមពលរួមបញ្ចូលគ្នា (Integrated Power Package) ពីក្រុមហ៊ុន GE ដែលរួមបញ្ចូលក្នុងម៉ាស៊ីនកម្តៅ ប្រព័ន្ធម៉ាស៊ីនភ្លើងអគ្គិសនី និងបង្កើតចំហាយទឹក តែគាត់ទាំង២មិនបញ្ជាក់ពីទឹកប្រាក់នៃកិច្ចព្រមព្រៀងនេះទេ។

លោក Massimo Gallizioli នាយកប្រតិបត្តិពាណិជ្ជកម្មសម្រាប់អាជីវកម្មប្រព័ន្ធថាមពលចំហាយទឹករបស់ក្រុមហ៊ុន GE ក្នុងតំបន់អាស៊ាន បានលើកឡើងថា នេះជាលើកទីមួយសម្រាប់ក្រុមហ៊ុនលោក ដែលទទួលបានកិច្ចសហការដៃគូដើម្បីចូលរួមដំណើរការគម្រោងផលិតថាមពលនៅកម្ពុជា ហើយក៏ជាលើកដំបូងនៅក្នុងតំបន់អាស៊ានសម្រាប់គម្រោងផ្តល់សេវាជាកញ្ចប់សម្រាប់ថាមពលរួមបញ្ចូលគ្នា នេះដើម្បីផលិតថាមពលចន្លោះពី ១០០ ទៅ ៣០០ មេហ្គាវ៉ាត់។ លោកថ្លែងថា «យើងជឿជាក់ថា គម្រោងរោងចក្រធ្យូងថ្មរបស់ក្រុមហ៊ុន CEL II នឹងក្លាយជាគំរូដ៏ល្អមួយ សម្រាប់បង្ហាញដល់បណ្តាប្រទេសកំពុងលូតលាស់ផ្សេងទៀត ដែលកំពុងត្រូវការប្រភពថាមពលស្រដៀងគ្នានេះ»។

ក្រុមហ៊ុន CEL II បានចុះបញ្ជីពាណិជ្ជកម្មនៅកម្ពុជានៅឆ្នាំ២០១៦ដែលមានភាគហ៊ុនិក និងក្រុមប្រឹក្សាភិបាលដូចគ្នានឹងក្រុមហ៊ុន Cambodian Energy Co Ltd (CEL) ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនម៉ាឡេស៊ី Leader Universal Holding ដែលបានវិនិយោគលើរោងចក្រអគ្គិសនីដើរដោយធ្យូងថ្មដំបូងគេនៅកម្ពុជា។ បច្ចុប្បន្ន CEL កំពុងដំណើរការដោយផលិតអគ្គិសនី ១០០ មេហ្គាវ៉ាត់ មានទីតាំងនៅខេត្តព្រះសីហនុដូចគ្នា។ រោងចក្រអគ្គិសនីដើរដោយធ្យូងថ្មទីពីរ គឺជាការរួលសហការវិនិយោគដោយក្រុមហ៊ុនចិន និងក្រុមហ៊ុនក្នុងស្រុក ដែលមានអានុភាពផលិតថាមពល ៧០០ មេហ្គាវ៉ាត់ ដែលបច្ចុប្បន្នកំពុងដំណើរការផ្នែកខ្លះ។

លោក កែវ រតនៈ អគ្គនាយកអគ្គិសនីកម្ពុជា EDC បានលើកឡើងកាលពីម្សិលមិញថា គិតមកទល់ពេលនេះ មានភូមិឃុំមួយចំនួនតូចនៅកម្ពុជានៅមិនទាន់មានការផ្គត់ផ្គង់អគ្គិសនី ដោយសារថាមិនទាន់មានខ្សែបណ្តាញតភ្ជាប់គ្រប់គ្រាន់ ខណៈដែលប្រភពថាមពលក្នុងស្រុករួមទាំងការទិញពីប្រទេសជិតខាង អាចឲ្យកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការក្នុងស្រុក។

លោកលើកឡើងថា ការវិនិយោគលើរោងចក្រធ្យូងថ្មនាពេលនេះគឺដើម្បីត្រៀមផលិតថាមពលដើម្បីបំពេញតម្រូវការអគ្គិសនីនាពេលខាងមុខ ដែលលោកព្យាករថានឹងមានកំណើនខ្លាំងសម្រាប់ឆ្នាំ២០១៩ និង ២០២០ ខាងមុខ។

លោកថ្លែងថា៖ «ប្រសិនបើមិនមានការវិនិយោគលើរោងចក្រផលិតអគ្គិសនីបន្ថែមនាពេលនេះ នៅឆ្នាំ២០១៩ ជាមួយនឹងកំណើនសេដ្ឋកិច្ចដ៏លឿនរហ័សរបស់ប្រទេសកម្ពុជា ដូចនៅពេលបច្ចុប្បន្ន យើងនឹងមានការខ្វះខាតអគ្គិសនីប្រើប្រាស់»។ លោកបានបន្តថា នេះជាមូលហេតុដែលរដ្ឋាភិបាលត្រូវចាប់ផ្តើមមានវិធានការជំរុញការវិនិយោគបន្ថែមនាពេលនេះ ដើម្បីធានាបានថាកម្ពុជាមានលទ្ធភាពផ្គត់ផ្គង់អគ្គិសនីគ្រប់គ្រាន់ស្របតាមតម្រូវការ។ លោកបានបញ្ជាក់ថា៖ «ការវិនិយោគនាពេលនេះនឹងជួយធានាថារោងចក្រនឹងអាចដំណើរការបានល្អ ដើម្បីផ្តល់ការងារដល់ប្រជាជននិងដើម្បីធានាថា ប្រជាជនគ្រប់ភូមិ ឃុំ មានអគ្គិសនីប្រើប្រាស់នាពេលខាងមុខ»។

ដើម្បីគាំទ្រដល់ការអភិវឌ្ឍនិងគម្រោងថាមពលអគ្គិសនីរបស់ប្រទេសកម្ពុជា កាលពីម្សិលមិញក្រុមហ៊ុន GE ក៏បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងរ៉ែ និងថាមពលកម្ពុជា ដែលក្រុមហ៊ុន GE នឹងអនុវត្តប្រព័ន្ធពិនិត្យតាមដាន និងវិភាគទិន្នន័យនូវកម្រិតបំភាយឧស្ម័នពុលតាមតំបន់នៅក្នុងរោងចក្រថាមពលទាំងអស់នៅទូទាំងប្រទេសរួមទាំងរោងចក្រថាមពលរបស់ក្រុមហ៊ុន CEL II ដែលកំពុងប្រតិបត្តិការផងដែរ។ LA ■

## អ្នកប្រើប្រាស់Twitter កើនឡើងខ្ពស់ ប៉ុន្តែប្រាក់ចំណូលធ្លាក់ចុះ

**ក្រុងវ៉ាស៊ីនតោន:** ក្រុមហ៊ុន Twitter បានឲ្យដឹងកាលពីថ្ងៃពុធថា កំណើនអ្នកប្រើប្រាស់របស់ខ្លួនបានកើនឡើងនៅត្រីមាសកន្លងមក ដែលផ្តល់ចក្ខុវិស័យសុទិដ្ឋិនិយម ទោះបីជាការធ្លាក់ចុះប្រាក់ចំណូល និងការខាតបង់ផ្សេងទៀតសម្រាប់បណ្តាញសង្គមមួយនេះក៏ដោយ។

លទ្ធផលត្រីមាសទី១ បានទទួលល្អជាងការព្យាករភាគច្រើន ដែលផ្តល់កំណើនមុនការបើកដំណើរការផ្លូញផ្លូ សម្រាប់ភាគហ៊ុននៅក្នុងក្រុមហ៊ុន Twitter ដែលបានជម្នះក្នុងការរក្សាល្បឿននៃព័ត៌មានសង្គមដ៏ឆាប់រហ័សរបស់ពិភពលោកមួយនេះ។

ការវាស់វែងតាមរយៈការប្លុំមើលយ៉ាងជិតដល់នៃអ្នកប្រើប្រាស់យ៉ាងសកម្មប្រចាំខែបានកើនឡើង៩ភាគរយធៀបនឹងរយៈពេលដូចគ្នាមួយឆ្នាំកន្លងមក រហូតដល់៣២៨លាននាក់ ខណៈអ្នកប្រើប្រាស់ប្រចាំឆ្នាំយ៉ាងសកម្មបានកើនឡើង១៤ភាគរយ។

ការខាតបង់សុទ្ធបានធ្លាក់ចុះពី៨០លានដុល្លារមកនៅត្រឹម៦២លានដុល្លារកាលពីឆ្នាំ២០១៥ សម្រាប់ក្រុមហ៊ុន Twitter ដែលមិនបានរាយការណ៍ប្រាក់ចំណេញពីមុននោះទេ។ ទន្ទឹមនឹងនេះប្រាក់ចំណូលរបស់ក្រុមបានធ្លាក់ចុះ៨ភាគរយមកនៅត្រឹម៥៤៨លានដុល្លារ ដែលជាចម្ងល់កំពុងបង្កបញ្ហាសម្រាប់ក្រុមហ៊ុនព័ត៌មានសង្គមមួយនេះ ប៉ុន្តែតួលេខមិនអាក្រក់ដូចការប៉ាន់ស្មាននោះទេ។

ដោយឡែកតម្លៃភាគហ៊ុនរបស់ក្រុមហ៊ុន Twitter បានកើនឡើងជិត៥ភាគរយនៅមុនពេលការបើកដំណើរការផ្លូញផ្លូ ដែលវាបានបង្ហាញពីការបន្ធូរបន្ថយក្តីបារម្ភអំពីផ្លូវទៅមុខសម្រាប់ក្រុមហ៊ុន Twitter ។

លោក Jack Dorsey ប្រធានប្រតិបត្តិបានឲ្យដឹងនៅក្នុងសេចក្តីប្រកាសព័ត៌មានមួយថា៖ «យើងកំពុងដាក់ចេញគោលដៅរបស់យើងក្នុងការបង្កើតសេវាដែលមនុស្សចូលចិត្តប្រើប្រាស់ ជារៀងរាល់ថ្ងៃ ហើយយើងត្រូវបានជំរុញដោយសម្ទុះកំណើនអតិថិជនដែលយើងទទួលបាននៅត្រីមាសទី១»។

លោកបានថ្លែងថា៖ «ខណៈដែលយើងបន្តប្រឈមនឹងឧបសគ្គប្រាក់ចំណូល យើងជឿជាក់ថា ការអនុវត្តតាមផែនការរបស់យើង និងកំណើនអតិថិជនរបស់យើងគួរតែធ្វើឲ្យមានកំណើនប្រាក់ចំណូលវិជ្ជមាននៅក្នុងរយៈពេលវែង»។ AFP/LA ■